ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្មដំណាំត្រឡាច




រៀបចំដោយ

**នាយកដ្ឋានគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**
**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ធ.អ.ជ.ក)**


ខែតុលា ឆ្នាំ២០២៥

# មាតិកា


១- សេចក្ដីផ្ដើម ..... ១

២- ការអនុវត្តការដាំដុះ ..... ១

ក- ការរៀបចំដី និងប្រព័ន្ធស្រោចស្រព ..... ១

ខ- ល្បាយដីបណ្ដុះកូន ..... ១

គ- ការជ្រើសរើសពូជ ..... ១

ឃ- វិធីដាំដុះ ..... ២

ង- ការថែទាំ ..... ២

ច- ការដាក់ជី ..... ២

ឆ- កត្តាចង្រៃ ..... ៣

ជ- អាយុកាលដាំដុះ និងប្រមូលផល ..... ៣

៣- តម្រូវការទុនដំបូងក្នុងការដាំដុះត្រឡាច លើផ្ទៃដីទំហំ ១០ អា ..... ៤

៤- ការវិភាគសេដ្ឋកិច្ចលើការដាំដុះត្រឡាច លើផ្ទៃដីទំហំ ១០ អា ..... ៤

៥- លទ្ធភាពចំណេញផ្អែកលើនិន្នាការតម្លៃ លើផ្ទៃដីទំហំ ១០ អា ..... ៥

៦- ខ្សែច្រវាក់តម្លៃ ..... ៦

៧- ហានិភ័យ ..... ៦

៨- សេចក្ដីសន្និដ្ឋាន ..... ៧

# ដំណាំត្រឡាច

## ១-សេចក្ដីផ្ដើម

ត្រឡាច គឺជាដំណាំប្រភេទវល្លិដែលអាចវារលើដីផ្ទាល់ ឬឡើងទ្រើង មានផ្លែមូលទ្រវែង ឬមូលខ្លី តាមប្រភេទនៃពូជ ដោយដុះលូតលាស់បានគ្រប់រដូវកាល លើប្រភេទដីល្បាប់ ដីល្បាយខ្សាច់ និងដីមានជីជាតិផ្សេងទៀត ដែលមានpHដីសមស្របនៅចន្លោះពី៥.៥-៦.៥ ជាមួយពន្លឺព្រះអាទិត្យយ៉ាងតិច៦ម៉ោងក្នុងមួយថ្ងៃ ដោយមានសីតុណ្ហភាពពី២១-៣០អង្សាសេ។ ផ្លែត្រឡាចខ្ចី ឬទុំ ត្រូវបានគេប្រើប្រាស់ក្នុងការចម្អិនអាហារខ្មែរ ដូចជាសម្លរ ឆា និងធ្វើបង្អែមជាដើម។ ក្រៅពីនេះ ត្រឡាចក៏មានអត្ថប្រយោជន៍ចំពោះសុខភាពជាច្រើនផងដែរ ដូចជាជួយសម្រួលដល់ការរំលាយអាហារ កាត់បន្ថយកម្ដៅក្នុងខ្លួន និងផ្ដល់វីតាមីនជាច្រើនប្រភេទ។

## ២-ការអនុវត្តការដាំដុះ

**ក. ការរៀបចំដី និងប្រព័ន្ធស្រោចស្រព÷** កសិករត្រូវភ្ជួរដីឱ្យម៉ដ្ឋល្អ រួចហាលដីទុករយៈពេលពី ១០ ទៅ ១៥ថ្ងៃ។ កសិករត្រូវប្រើប្រាស់ជីធម្មជាតិទ្រាប់បាតក្នុងបរិមាណ ៥០០ ទៅ ១,៥០០ គីឡូក្រាម/១០០០ម៉ែត្រការ៉េ(តាមលទ្ធភាព និងគុណភាពដី) បន្ទាប់មកឆ្ងួតពូនជារងដែលមានទទឹងរងខាងលើ ០.៦ម៉ែត្រ និងបាតរង ០.៨ម៉ែត្រ កម្ពស់ ០.២-០.៣ម៉ែត្រ ដោយពីពាក់កណ្ដាលរងមួយទៅពាក់កណ្ដាលរងមួយប្រវែង ១.៥ម៉ែត្រ ដោយដាក់ប្រព័ន្ធស្រោចស្រពដំណក់ទឹកពីលើរងបន្លែ គ្របដោយកៅស៊ូគ្របរង និងមានប្រព័ន្ធប្រឡាយជុំវិញចម្ការ។

**ខ. ល្បាយដីបណ្ដុះកូន ÷** ល្បាយដីបណ្ដុះត្រូវមានវត្ថុធាតុដើមសំខាន់ៗដូចជា ដីដំបូក ឬដីទន្លេ ១/៣ ធ្យូងអង្កាម ១/៣ និងកំប៉ុស១/៣ ដោយច្របល់ចូលគ្នា បន្ទាប់មកយកទៅលីង ឬចំហុយសម្លាប់មេរោគ និងគ្រាប់ស្មៅចង្រៃ។

**គ. ការជ្រើសរើសពូជ÷** កសិករអាចជ្រើសពូជត្រឡាចមួយចំនួនដែលមានវត្តមាននៅកម្ពុជា




នីលីជា
ត្រឡាច ១៦៨ F1




TKS
ពូជត្រឡាចស្រែ



East-West Seed
ពូជស្រឡូន




KsSeed
ពូជណៃស៊ីម០១

**ឃ. វិធីដាំដុះ÷** កសិករត្រូវយកកូនត្រឡាចដែលបណ្ដុះបានអាយុពី១៨ ទៅ ២៥ថ្ងៃ ពីថាសបណ្ដុះមកដាំលើរងដែលបានគ្របកៅស៊ូរួចរាល់ ដោយដាំតែ១ជួរនៅលើរង ក្នុងចន្លោះគុម្ព៦០-៨០ស.ម បង្គោលទ្រើងមានកម្ពស់២ម៉ែត្រ ចន្លោះបង្គោលមានប្រវែង២ម៉ែត្រ ប្រើប្រាស់សំណាញ់ទ្រើងបញ្ឈរភ្ជាប់បង្គោលទ្រើងនីមួយៗ និងអាចបន្ថែមសំណាញ់ទ្រើងជាដំបូលតាមលទ្ធភាព ដើម្បីងាយស្រួលគ្រប់គ្រងកម្តៅ កត្តាចង្រៃ និងការប្រមូលផល។





**ង. ការថែទាំ÷** ត្រូវស្រោចទឹកក្នុងមួយថ្ងៃ២ដង គឺនៅពេលព្រឹក និងពេលរសៀល ផ្អែកលើសំណើមដីជាក់ស្ដែង។ នៅក្នុងចម្ការត្រូវសម្អាតស្មៅចង្រៃនៅតាមចន្លោះរងឱ្យបានស្អាត ដើម្បីកម្ចេចជម្រកសត្វល្អិត និងប្រភពជំងឺដំណាំ។ ដំណាំត្រឡាចត្រូវតាក់តែងមែក ស្លឹកផ្នែកខាងក្រោមមួយចំនួន ដើម្បីដើមត្រឡាចឡើងទ្រើងបានខ្ពស់ ចេញផ្លែបានច្រើន និងកាត់បន្ថយជំងឺ។

**ច. ការដាក់ជី÷** ដំណាំត្រឡាចក្រោយដាំបានរយៈពេល៧ថ្ងៃ កសិករគប្បីមានកម្មវិធីប្រើប្រាស់ជីដែលបរិមាណប្រែប្រួលទៅតាមស្ថានភាពលូតលាស់របស់ដំណាំ កសិករក៏អាចប្រើប្រាស់ប្រភេទជីទឹកនៅដំណាក់កាលលូតលាស់ តាមប្រព័ន្ធដំណក់ទឹក និងការបាញ់បន្ថែមទៅលើស្លឹក។ សារធាតុជីចម្បងៗមានបីប្រភេទគឺ÷ N P K ដែលជាតម្រូវការចាំបាច់សម្រាប់ការដុះលូតលាស់ ភាពធន់ទៅនឹងជំងឺ សត្វល្អិត និងផ្កាផ្លែ។ ចំណែកសារធាតុបន្ថែម Trace Element(TE) បានជួយដល់គុណភាពផលិតផល ទិន្នផលខ្ពស់ និងរូបរាងស្រស់ស្អាត។

**ឆ. កត្តាចង្រៃ÷** ជាទូទៅកសិករតែងជួបប្រទះជាញឹកញាប់នូវកត្តាចង្រៃដែលបំផ្លាញដំណាំត្រឡាចមានដូចជា÷ អណ្ដើកមាស ដង្កូវមីឡុន ដង្កូវស៊ីញ៉ៅ រុយស រុយទិចផ្លែ មមាចខៀវ ពីងពាងក្រហម ទ្រីប ជំងឺផ្សិត-បាក់តេរី និងវីរុសជាដើម។











**ជ. អាយុកាលដាំដុះ និងប្រមូលផល÷** អាយុកាលដំណាំត្រឡាចមានរយៈពេលពី ៤-៦ខែ អាចប្រមូលផលនៅអាយុពី ៥០-៦០ថ្ងៃ ក្រោយពេលដាំកូន។ ត្រឡាចដែលមានតម្រូវការនៅលើទីផ្សារគឺជាផ្លែខ្ចីមានទម្ងន់ ០.៥-១ គីឡូក្រាម/ផ្លែ។ ឧបករណ៍ប្រមូលផលមានដូចជា កន្ត្រៃ ឬកាំបិតមុតកាត់ផ្តាច់ទងដោយមិនឱ្យប៉ះទង្គិចផ្លែ បន្ទាប់មកអាចច្រកក្នុងថង់ ឡាំងកេះដែលធ្វើពីជ័រ ឬក្រដាស់ស្ងួត (បើសិនជាមានលទ្ធភាពត្រូវបញ្ជូនទៅរក្សាទុកនៅឃ្លាំងត្រជាក់ ដើម្បីរក្សាគុណភាព និងរក្សាទុកបានយូរ)។ ទិន្នផលគឺអាស្រ័យទៅលើប្រភេទពូជ លក្ខខណ្ឌអាកាសធាតុ ការដាំដុះ និងការថែទាំ។






**៣-គម្រោងការទុនដំបូងក្នុងការដាំដុះត្រសក់** លើផ្ទៃដីទំហំ ១០ អា

| បរិយាយ | ចំនួនទឹកប្រាក់ (រៀល) |
|---|---|
| ចំណាយលើការដាំដុះ | 1,459,000 |
| ចំណាយលើប្រព័ន្ធស្រោចស្រព | 5,210,000 |
| សម្ភារៈផ្សេងៗ | 1,950,000 |
| **សរុប** | **8,619,000** |

**៤-ការវិភាគសេដ្ឋកិច្ចលើការដាំដុះដំណាំត្រសក់** លើផ្ទៃដីទំហំ ១០ អា

-បទពិសោធន៍÷ ការដាំដុះរបស់កសិករនៅសង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

-ទិន្នផលមធ្យម÷ ៣,៥០០ គ.ក/១០អា

-តម្លៃបោះដុំពីចម្ការ÷ ១,៦០០រៀល/គ.ក

-ចំនួនវគ្គក្នុងមួយឆ្នាំ÷ ២វគ្គក្នុងមួយឆ្នាំ

| បរិយាយ | ឯកតា | ចំនួនឯកតា | តម្លៃ/ឯកតា (រៀល) | ទឹកប្រាក់ (រៀល) | ចំនួនសាររំលស់ | ទឹកប្រាក់សរុប (រៀល) |
|---|---|---|---|---|---|---|
| **១-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល** | | | | | | 2,084,000 |
| **១.ក-ចំណាយប្រែប្រួលសរុប** | | | | | | 1,459,000 |
| ភ្ជួរដី និងលើករង | លើក | 3 | 30,000 | 90,000 | | 90,000 |
| ពូជ | កញ្ចប់ | 7 | 22,000 | 154,000 | | 154,000 |
| ជីកំប៉ុស (លាមកគោ) | តោន | 1 | 135,000 | 135,000 | | 135,000 |
| ជីគីមីគ្រាប់ | ការ៉ុង | 1 | 170,000 | 170,000 | | 170,000 |
| ជីទឹក បំប៉ន | ឈុត | 1 | 100,000 | 100,000 | | 100,000 |
| ថ្នាំសម្លាប់សត្វល្អិត + ជំងឺ | ឈុត | 1 | 100,000 | 100,000 | | 100,000 |
| ឈ្នួលកម្មករដាំ និងថែទាំ | នាក់ | 15 | 30,000 | 450,000 | | 450,000 |
| ប្រេងម៉ាស៊ូត | លីត្រ | 60 | 3,500 | 210,000 | | 210,000 |
| ចំណាយផ្សេងៗ | វគ្គ | 1 | 50,000 | 50,000 | | 50,000 |
| **១.ខ-ចំណាយមិនប្រែប្រួលសរុប** | | | | | | 625,000 |
| ប្រព័ន្ធទឹកមេ (៥ឆ្នាំ) | ឈុត | 1 | 250,000 | 250,000 | 10 | 25,000 |
| ប្រព័ន្ធទឹកស្រោចស្រព(២ឆ្នាំ) | ឈុត | 1 | 360,000 | 360,000 | 4 | 90,000 |

| | | | | | | |
|---|---|---|---|---|---|---|
| ម៉ាស៊ីនបូមទឹក១២សេះ(១០ឆ្នាំ) | គ្រឿង | 1 | 1,600,000 | 1,600,000 | 20 | 80,000 |
| ធុងបាញ់ថ្នាំ ( ៣ឆ្នាំ ) | គ្រឿង | 1 | 120,000 | 120,000 | 6 | 20,000 |
| កៅស៊ូគ្របរង( ២លើក) | ដុំ | 3 | 75,000 | 225,000 | 2 | 112,500 |
| សំណាញ់ទ្រើង( ២លើក) | ដុំ | 15 | 9,000 | 135,000 | 2 | 67,500 |
| ថាសបណ្ដុះកូន( ៣លើក) | បន្ទះ | 30 | 3,000 | 90,000 | 3 | 30,000 |
| បង្គោលទ្រើងឈើ( ៥ឆ្នាំ) | ដើម | 325 | 4,000 | 1,300,000 | 10 | 130,000 |
| ខ្សែជ័រខ្មៅ ( ប្រើ២ឆ្នាំ) | គីឡូ | 20 | 4,000 | 80,000 | 4 | 20,000 |
| អណ្ដូងទឹក ( ប្រើ៣០ឆ្នាំ ) | ឈុត | 1 | 3,000,000 | 3,000,000 | 60 | 50,000 |
| **២-ចំណូលពីការលក់ត្រឡាច** | | | | | | 5,600,000 |
| ប្រមូលផលសរុប | គ.ក | 3,500 | 1,600 | 5,600,000 | | 5,600,000 |
| **៣-ចំណេញ-ខាត** | | | | | | 3,516,000 |
| ថ្លៃដើមផលិត/ គ.ក = ចំណាយសរុប/ ទិន្នផលសរុប | | | | | | 595 |
| ចំណេញ/ គ.ក = ចំណេញសរុប/ ទិន្នផលសរុប | | | | | | 1,005 |

## **៥-លទ្ធភាពចំណេញផ្អែកលើនិន្នាការតម្លៃ** ÷ ( លើផ្ទៃដីដាំដុះ១០ អា)

- តម្លៃទាបបំផុត ១,០០០៛/ គ.ក
- តម្លៃខ្ពស់បំផុត ១,៨០០៛/ គ.ក

| **ទិន្នផល** | **តម្លៃ** | **ចំណូល** | **ចំណាយ** | **ចំណេញ- ខាត** | |
|---|---|---|---|---|---|
| **គ.ក** | **រៀល/ គ.ក** | **រៀល** | **រៀល** | **រៀល** | **%** |
| 3,500 | 1,000 | 3,500,000 | 2,084,000 | 1,416,000 | 67.95% |
| 3,500 | 1,200 | 4,200,000 | 2,084,000 | 2,116,000 | 101.54% |
| 3,500 | 1,400 | 4,900,000 | 2,084,000 | 2,816,000 | 135.12% |
| 3,500 | 1,600 | 5,600,000 | 2,084,000 | 3,516,000 | 168.71% |
| 3,500 | 1,800 | 6,300,000 | 2,084,000 | 4,216,000 | 202.30% |

## ៦-ខ្សែច្រវាក់តម្លៃ ÷

**កសិករ ÷** លក់ ១,៦០០៛/គ.ក - ថ្លៃដើម ៥៩៥៛/គ.ក = ចំណេញ ១,០០៥៛/គ.ក

**ឈ្មួញកណ្ដាល ÷** លក់ ២,០០០៛/គ.ក(ថ្លៃដឹកជញ្ជូន ២០០៛/គ.ក) ចំណេញ ២០០៛/គ.ក

**អ្នកលក់រាយ ÷** លក់៣,០០០៛/គ.ក(ជួលតូប និងខូចខាត៥០០៛/គ.ក) ចំណេញ ៥០០៛/គ.ក

## ៧-ហានិភ័យ ÷

តាមការសិក្សាផ្ទាល់ជាមួយកសិករដាំដុះត្រឡាចនៅសង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ អាចមានហានិភ័យមួយចំនួនកើតឡើងជាយថាហេតុលើដំណើរការដាំដុះដំណាំត្រឡាចដូចជា÷

| ល.រ | ប្រភេទហានិភ័យ | ពិពណ៌នាហានិភ័យ | វិធានការ |
|---|---|---|---|
| ១ | **ហានិភ័យផលិតកម្ម** | ទិន្នផលធ្លាក់ចុះបណ្ដាលមកពី÷<br>-កត្តាសត្វល្អិតចង្រៃ<br>-កត្តាជំងឺដំណាំ<br>-កត្តាគុណភាពដី<br>-បម្រែបម្រួលអាកាសធាតុ | -គួរប្រើប្រាស់វិធានការការពារដំណាំ និងមានកាលវិភាគប្រើប្រាស់ថ្នាំត្រឹមត្រូវសម្រាប់សត្វល្អិត និងជំងឺ<br>-ប្រើប្រាស់ថ្នាំជីវសាស្ត្រ មុនពេលចាប់ផ្ដើមដាំដុះ<br>-ជ្រើសរើសពូជធន់នឹងកត្តាចង្រៃ អាកាសធាតុពិសេសពូជក្នុងស្រុក ដែលមិនមានជំងឺវីរុស និងរក្សាទុកបានត្រឹមត្រូវ<br>-សិក្សាការកែប្រែគុណភាពដី និងបន្ថែមការគ្រប់គ្រងដីឱ្យស្របតាមតម្រូវការជីរបស់ដំណាំ |
| ២ | **ហានិភ័យទីផ្សារ** | ពីខែវិច្ឆិកា ដល់ខែកុម្ភៈ និងខែឧសភា ដល់ខែតុលា តម្លៃធ្លាក់ចុះដោយសារ<br>-អាកាសធាតុអំណោយផល<br>-កសិករដាំដុះតាមផ្ទះច្រើន | -ពង្រីកបណ្ដាញទីផ្សារឱ្យបានច្រើន និងព័ត៌មានទីផ្សារជាប្រចាំ ដើម្បីពង្រឹងទីផ្សារ<br>-ចងក្រងក្រុមផលិត ដើម្បីធ្វើកិច្ចព្រមព្រៀងទិញ-លក់ និងធ្វើផែនការផលិតតាមកិច្ចសន្យា<br>-ផលិតដំណាំចម្រុះ ជាជាងដំណាំតែមួយមុខ<br>-ជំរុញឱ្យមានការកែច្នៃជានំ ដំណាប់ ភេសជ្ជ<br>-ស្វែងរកព័ត៌មាននៃការដាំដុះនៅតំបន់ផ្សេងៗ ដើម្បីអាចជ្រើសរើសសម្រាប់ដាំដុះសមរម្យ |

## ៨-សេចក្តីសន្និដ្ឋាន

ត្រឡាច គឺជាដំណាំអាចលូតលាស់បានល្អ ស្ទើរតែគ្រប់ប្រភេទដី។ នៅរដូវមានភ្លៀងធ្លាក់ច្រើន និងកម្តៅខ្លាំងលើសពី៣៥អង្សាសេ ដំណាំត្រឡាចប្រឈមជាមួយជំងឺ និងសត្វល្អិតជាច្រើនប្រភេទ ដែលតម្រូវឱ្យមានការត្រួតពិនិត្យ និងវិធានការការពារជាប់ជាប្រចាំ។ ដំណាំត្រឡាចអាចផ្តល់ទិន្នផលរយៈពេលយូរគឺអាស្រ័យលើគុណភាពរបស់ដី ការគ្រប់គ្រងជីបានត្រឹមត្រូវ និងលក្ខខណ្ឌអាកាសធាតុសមស្របផងដែរ។ ប្រជាពលរដ្ឋដែលរស់នៅជនបទ និងទីប្រជុំជនសុទ្ធសឹងតែនិយមចូលចិត្តដំណាំត្រឡាច ជាហេតុធ្វើឱ្យមានតម្រូវការតាមទីផ្សារ និងមានឈ្មួញប្រមូលទិញពីចម្ការ ទៅលក់ចែកចាយបន្តទៅទីផ្សារក្នុងតំបន់ និងផ្សារនានា ដោយកសិករមានលទ្ធភាពចំណេញដោយលក់បោះដុំចេញពីចម្ការក្នុងតម្លៃក្នុងរង្វង់១,០០០៛/គ.ក ឬតម្លៃលើសពីនេះ។


ប្រភពសិក្សា÷

-កសិករដាំដុះដំណាំត្រឡាចនៅសង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

-ឯកសារក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-https://a-z-animals.com/blog/thrips-identification-guide-how-to-spot-these-pesky-pests/

-https://www.koppert.co.uk/plant-pests/leaf-miners/tomato-leaf-miner/

-https://revistacultivar.com/articles/management-of-diaphania-hyalinata-caterpillars-in-Japanese-pumpkin-cultivation